# ការសម្ភាសន៍របស់លោកពូ ម៉ាក ស្រ៊ុន ហុង

កៈ អ្នកសម្ភាសន៍ឈ្មោះ រត្ន ពិសី ខៈ អ្នកដែរគេត្រូវសម្ភាសន៍ ម៉ាក ស្រ៊ុនហុង

## ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ ម៉ាក ស្រ៊ុនហុង

ជីវប្រវត្តិសង្ខេបរបស់លោកពូមានការលំបាកហើយមានការជួបឧបសគ្គជាច្រើនដែរលោកពូឆ្លងកាត់ព្យុះភ្លៀងមួយនេះដោយលំបាកហើយលោកពូជាមនុស្សស្លូតបូតហើយមានភាពមេត្តាហើយចេះរាប់អានអ្នកដ៏ទៃ។ធ្វើឡើងនៅភូមិ ប្រាសាទ ស្រុក ស្អាង ខេត្ត កណ្តាល

ធ្វើឡើងនៅថ្ងៃទី១៥ ខែ ០៥ ឆ្នាំ ២០១៨។

កៈ ជាដំបូងខ្ញុំសូមជំរាប់សួរលោកពូខ្ញុំបាទឈ្មោះ រត្ន ពិសី
ខ្ញុំសូមអនុញ្ញាតលោកពូធ្វើការសម្ភាសន៍ជីវប្រវត្តិរបស់លោកពូដោយក្មួយធ្វើឡើងដោយសាលកវិទ្យាល័យមួយដែលមានឈ្មោះថា “ ប៊ី វ៉ាយ យូវ “
ដែរមានទីតាំងនៅសហរដ្ឋអាមេរិចលោកពូដើម្បីថែរក្សាជីវប្រវត្តិរបស់លោកពូហើយដើម្បីថែរក្សាជីវប្រវត្តិជីដូនតារបស់លោកពូផងដែរអញ្ចឹងលោកពូដើ
ម្បីទុកឲ្យកូនចៅជំនាន់ក្រោយឲ្យគាត់បានស្តាប់ហើយឲ្យគាត់បានដឹងថាអ្នកជំនាន់មុនមានការលំបាកអ្វីខ្លះនៅក្នុងជីវិតរបស់មនុស្សជំនាន់មានជួបឧបសគ្គអ្វីខ្លះ

អញ្ចឹងណាស់។

ខៈ បាទ!

កៈ បាទ! អញ្ចឹងក្មួយធ្វើឡើងនៅថ្ងៃទី ១៥ ខែ ០៥ ឆ្នាំ ២០១៨ ។

ខៈ បាទ!

កៈ ហើយអញ្ចឹងនៅនិងគេហៅភូមិអីគេដែរលោកពូ?

ខៈ អត់ដឹងថាភូមិអីទេគេហៅមកធ្វើផ្ទះឲ្យគេនិង។

កៈ អរ បាទ! លោកពូមកធ្វើជាងផ្ទះឲ្យគេលោកពូ។

ខៈ បាទ! បើស្រុកកំណើតខ្ញុំនៅ ស្អាង ព្រៃតូច ទេ។

កៈ បាទ! អញ្ចឹងពូនៅស្រុក ស្អាង ព្រៃតូចនិងពូ។

ខ៖ បាទ!

ក៖ អញ្ចឹងអត់ទោសលោកពូមានឈ្មោះអីគេដែរលោកពូ?

ខ៖ ខ្ញុំឈ្មោះម៉ាក ស្រ៊ុនហុង ។

ក៖ លោកពូឈ្មោះ ម៉ាក ស្រ៊ុនហុង។

ខ៖ បាទ!

ក៖ បាទ! ម៉ាក ស្រ៊ុនហុងហើយអញ្ចឹងលោកពូមានអាយុប៉ុន្មានដែរ?

ខ៖ ខ្ញុំមានអាយុ៥៦ហើយ។

ក៖ បាទ! អញ្ចឹងពូមានអាយុ៥៦ឆ្នាំលោកពូ។

ខ៖ បាទ!

ក៖ អញ្ចឹងលោកពូមានឈ្មោះហៅខាងក្រៅទេ?

ខ៖ អត់មានទេ។

ក៖ បាទ! អញ្ចឹងអត់មានទេពូ?

ខ៖ បាទ!

ក៖ បាទ! ហើយលោកពូមានដឹងថាពូមានកើតនៅឆ្នាំណាទេពូ?

ខ៖ ខ្ញុំអត់ដឹងទេថាកើតឆ្នាំណាទេ។

ក៖ បាទ!អញ្ចឹងលោកពូអត់មានទេ។

ខ៖ ខ្ញុំប្រហែល១៩៦២ ។

ក៖ បាទ! ឆ្នាំ១៩៦២ពូ ។

ខ៖ បាទ! ខ្ញុំមានអាយុ៦២ឆ្នាំហើយ។

ក៖ បាទ!ចឹងបើឆ្នាំខ្មែរវិញណាស់លោកពូតើលោកពូកើតនៅឆ្នាំណាដែលលោកពូ?

ខ៖ ខ្ញុំកើតឆ្នាំថោះឆ្នាំទន្សាយ។

កៈ
បាទ!ដល់ពេលយូរពេលចង់ភ្លេចឆ្នាំខ្លួនឯងបាទចឹងលោកពូតើស្រុកកំណើតរបស់លោកពូនៅខេត្តណាដែលលោកពូ?

ខៈ ស្រុកកំណើតរបស់ខ្ញុំនៅភូមិប្រាសាទស្រុកស្អាងខេត្តកណ្តាល។

កៈ
បាទ!នឹងជាស្រុកកំណើតរបស់លោកពូដែលបានកើតនៅទីនោះផ្ទាល់តែម្តងណាស់លោកពូ?

ខៈ បាទ!

កៈ បាទ!ចឹងតើលោកពូមានបងប្អូនបង្កើតប៉ុន្មាននាក់ដែលលោកពូ?

ខៈ ខ្ញុំមានបងប្អូនបង្កើត៧នាក់។

កៈ
បាទ!ចឹងលោកពូមានបងប្អូនបង្កើតសរុបតាំងអស់មាន៧នាក់បាទចឹងតើលោកពូជាកូនទីប៉ុន្មានដែរលោកពូ?

ខៈ ខ្ញុំជាកូនទី៤។

កៈ
បាទ!ចឹងលោកពូជាកូនទី៤ណាស់លោកពូបាទចឹងតើលោកពូអាចរាប់រៀបឈ្មោះបងប្អូនរបស់លោកពូបានទេលោកពូ?

ខៈ បាទ!ស្រ៊ុន ប៊ុនហេង ស្រ៊ុន ហ៊ុន ស្រ៊ុន លី ស្រ៊ុន ហុង ស្រ៊ុន ស្រីពៅ ស្រ៊ុន សុខជាតិ ស្រ៊ុន សុខតា។

កៈ
បាទ!ចឹងតើលោកពូមានចាំថាសាច់រឿងជាមួយពួកគាត់ណាស់លោកពូថាលោកពូធ្លាប់ធ្វើអ្វីខ្លះជាមួយគាត់ធ្លាប់ទៅណាជាមួយគ្នាអីណាស់លោកពូ?

ខៈ ជំនាន់កាលអាពតនឹងម៉ែន។

កៈ បាទ!តើលោកពូធ្លាប់ទៅណាជាមួយគ្នាទេលោកពូ?

ខ៖
កាលជំនាន់អាពតខ្ញុំឡើងមកធ្វើការតាំងពីតូចមកហើយខ្ញុំលាក់ខ្លួននៅនឹងដល់ហើយគេជំលៀសទៅធ្វើទ័ពហើយខ្ញុំធ្វើទ័ពបាន៣ខែបានគេបែកចេញមក។

ក៖
អរបាទ!ចឹងតើលោកពូធ្វើទ័ពខាងលន់នល់ឬមួយលោកពូធ្វើទ័ពអោយអាពតចឹងណាស់លោកពូ?

ខ៖ ខ្ញុំធ្វើទ័ពអោយខ្មែរក្រហម។

ក៖ អរបាទ!ចឹងលោកពូធ្វើទ័ពអោយខ្មែរក្រហម?

ខ៖ បាទ!កាលជំនាន់ខ្មែរក្រហម។

ក៖ បាទ!ពេលនឹងគេចាប់លោកពូឬមួយលោកពូចូលដោយសុខចិត្ត?

ខ៖ ខ្ញុំចូលដោយស្ម័គចិត្តដល់ហើយខ្ញុំធ្វើទ័ពនឹងបានបីខែគេវៃបែកម៉ង។

ក៖ អរបាទ!ចឹងលោកពូធ្វើបាន៣ខែគេវៃបែកទៅ?

ខ៖ បាទ!គេបែកម៉ង។

ក៖ បាទ!បែកខ្មែរក្រហមម៉ងលោកពូ?

ខ៖ បាទ!បែកខ្មែរក្រហមនឹង។

ក៖ អរចឹងលោកពូអត់មានសាច់រឿងអ្វីជាមួយបងប្អូនរបស់លោកពូទេ?

ខ៖ អរបងប្អូនខ្ញុំកាលជំនាន់នឹងបែកបាក់គ្នាអស់ហើយ។

ក៖ អរបាទ!ចឹងកាលជំនាន់អាពតបងប្អូនរបស់លោកពូបែកបាក់គ្នាអស់ហើយ?

ខ៖
បាទ!បែកគ្នានឹងមួយនៅខាងនោះទៅគេប្តូរស្រុកអត់ស្គាល់ឪពុកម្តាយបងប្អូនអត់ស្គាល់គ្នាទៀត។

ក៖
អរបាទ!ចឹងលោកពូកាលលោកពូនៅពីក្មេងណាស់លោកពូតើលោកពូចូលចិត្តធ្វើអ្វីខ្លះជាមួយពួកគាត់ទេលោកពូ?

ខ៖ ខ្ញុំកាលនៅពីក្មេងខ្ញុំអត់ដែលធ្វើអ្វីជាមួយពួកគាត់ទេ។

ក៖ បាទ!ចឹងលោកពូអត់ដែរទេលោកពូ?

ខ៖ បាទ!

ក៖
បាទ!ចឹងលោកពូបើជំនាន់អាពតលោកពូមានធ្លាប់គេអោយលោកពូទៅជីកដីធ្វើស្រែចំការអីណាស់លោកពូ?

ខ៖ បាទ!ខ្ញុំធ្លាប់ធ្វើតាគេអោយខ្ញុំលើកដីធ្វើស្រែចំការអីនឹង។

ក៖
អរបាទ!ចឹងនៅពេលនឹងលោកពូក៏ចូលធ្វើជាទាហានស្មាកចិត្តទៅ(ខ្មែរក្រហម)បាទចឹងនៅពេលនឹងតើគេជំលៀសលោកពូទៅដល់ណាដែរលោកពូ?

ខ៖ គេជំលៀសខ្ញុំតាំងពីស្រុកស្វាយរំរហូតដល់ទឹកខ្មៅនេះ។

ក៖ អរគេជំនៀសលោកពូមកដល់ទឹកខ្មៅទៀតលោកពូ?

ខ៖ បាទ!

ក៖ បាទ!ចឹងលោកពូនៅពេលនឹងតើលោកពូមានការលំបាកអ្វីខ្លះដែរលោកពូ?

ខ៖
បើការលំបាកនឹងវានិយាយលេងចេញទៅហើយតាំងពីចេកមួយអីបួសរៀនអស់ហើយ។

ក៖ អរបាទ!ចឹងលោកពូធ្លាប់បួសដែរលោកពូ?

ខ៖
អត់ទេខ្ញុំអត់បានបួសទេគ្រាន់តែខ្ញុំធ្លាប់សិក្សាអីចឹងណាស់តាំងពីផ្លែចេកមួយពោតមួយអីខ្ញុំធ្លាប់អស់ហើយ។

ក៖ បាទ!លោកពូធ្លាប់អស់ហើយបាទជីវិតជួរជត់ការពីជំនាន់នឹង?

ខ៖ បាទ!ដល់ពេលយើងហូបរួចចឹងយើងយកសំបកនឹងទៅចោលនៅព្រៃភ្នំទៀតណា។

ក៖ បាទ!

ខ៖ ឲ្យប្រជាជនយើងហូតបបរម៉ាចាននិង។

ក៖ ហូតបបរទៅអញ្ចឹងពូ។

ខ៖ បាទ!
ហើយបបរជូនកាលដូសមកបានពោតមួយទៅណាហើយហូបទឹកនិងទៅហើយទៅទៀតទៅ។

ក៖ បាទ! អញ្ចឹងលោកពូជួបការលំបាកច្រើនណាពូណុស។

ខ៖ បាទ! មានការលំបាកច្រើនណាស់។

ក៖ ហើយអញ្ចឹងលោកពូមានគេជំលៀសទៅណាទៀតទេពូ?

ខ៖
អត់មានជំលៀសទៅណាទៀតផងពេលនិងខ្មែរហើយនិងយួនវាយចូលមកតែម្តងទៅណា។

ក៖ បាទ! ហើយជំនាន់យួនមកវាយតែម្តងទៅពូ?

ខ៖ បាទ!

ក៖ អញ្ចឹងលោកពូមាននៅចាំឈ្មោះឪពុកម្តាយលោកពូទេលោកពូ?

ខ៖ ចាំតា។

ក៖ អញ្ចឹងលោកឪពុកមានឈ្មោះអីដែរលោកពូ?

ខ៖ ឪពុកខ្ញុំមានឈ្មោះ លន់ ហុង ។

ក៖ បាទ! ឈ្មោះ លន់ ហុង ឈ្មោះដូចពូដែរពូ។

ខ៖ បាទ!

ក៖ ហើយអ្នកម្តាយមានឈ្មោះអីដែរលោកពូ?

ខ៖ មានឈ្មោះ ឃឹម អួន ។

ក៖ ឈ្មោះ ឃឹម អួន
ហើយអញ្ចឹងលោកពូមាននៅចាំថាតែឥឡូវពួកគាត់បានស្លាប់ហើយលោកពូ។

ខ៖ គាត់ស្លាប់យូរហើយ។

កៈ បាទ!

ខៈ ហើយគាត់បានស្លាប់តាំងពីជំនាន់ដាច់អាពត។

កៈ បាទ! ហើយអញ្ចឹងលោកពូមានចាំថាគាត់បានស្លាប់នៅឆ្នាំណាទេលោកពូ?

ខៈ អត់ចាំទេថាគាត់ស្លាប់នៅឆ្នាំណាទេ។

កៈ បាទ! អញ្ចឹងលោកពូអត់ចាំទេពូ។

ខៈ បាទ!

កៈ បាទ! ហើយអញ្ចឹងលោកពូមាននៅចាំទីកន្លែងកំណើតរបស់គាត់ទេលោកពូ?

ខៈ គាត់នៅភូមិប្រាសាទដែរនិង។

កៈ គាត់នៅភូមិប្រាសាទដែរ។

ខៈ បាទ! គាត់នៅភូមិប្រាសាទដែរ។

កៈ អញ្ចឹងលោកពូមានចាំឆ្នាំខ្មែរគាត់ទេលោកពូ?

ខៈ អត់ចាំទេ។

កៈ អរលោកពូអត់ចាំទេលោកពូ។

ខៈ បាទ!

កៈ
ហើយអញ្ចឹងលោកពូមានចាំថាពេលនៅជំនាន់ប៉ុលពតនិងតើគាត់ប្រកបមុខរបរអីដើម្បីចិញ្ចឹមលោកពូហើយនិងបងប្អូនរបស់លោកពូ?

ខៈ នៅពេលជំនាន់អាពតគាត់ធ្វើស្រែចំការនិង។

កៈ បាទ! គាត់ស្រែចំការលោកពូ។

ខៈ បាទ!

កៈ ហើយគាត់ចិញ្ចឹមកូនទាំងអស់ទៅលោកពូ។

ខៈ បាទ!

កៈ ហើយអញ្ចឹងលោកពូជួយគាត់ដែរទៅ។

ខៈ ខ្ញុំជួយគាត់តា។

កៈ ហើយជួយគាត់ម៉ាដៃម៉ាជើងទៅលោកពូ។

ខៈ បាទ! ខ្ញុំជួយពួកគាត់ទៅ។

កៈ
ហើយអញ្ចឹងលោកពូមានដឹងថាឪពុកម្ដាយរបស់លោកពូមានចរឹតលក្ខណៈបែបណាដែរលោកពូ?

ខៈ អរ បើនិយាយឪពុកម្ដាយរបស់ខ្ញុំពួកគាត់ស្លូតទាំងពីរនាក់និង។

កៈ ហើយពួកគាត់អត់ដៃរវាយកូនទេលោកពូ?

ខៈ អត់ដៃរវាយកូនទេ។

កៈ បាទ!

ខៈ បើនិយាយគាត់ដៃរវាយកូនទាំងនិង។

កៈ បាទ! កាលពីរជំនាន់និងគេអត់ដៃរវាយកូនទេ។

ខៈ បាទ! អត់ទេ។

កៈ អញ្ចឹងលោកពូមាននៅចាំថាពួកគាត់ទៅណាគាត់យកលោកពូទៅតាមទេលោកពូ។

ខៈ គាត់ដែរនាំកូនទៅកំសាន្តហើយយកដែរ។

កៈ បាទ! ហើយនាំកូនទៅមើលកុនអីទៅលោកពូល្ខោននិងទៅ។

ខៈ បាទ! គាត់នាំទៅមើលកុនហើយទៅមើលល្ខោនអីអញ្ចឹងទៅ។

កៈ បាទ!
អញ្ចឹងលោកពូមាននៅចាំសាច់រឿងជាមួយពួកគាត់ថាមានភាពជូរជត់អីខ្លះហើយបានជួបឧបសគ្គអីខ្លះជាមួយគាត់ទេលោកពូ។

ខៈ ជាមួយបងប្អូនឬជាមួយឪពុកម្ដាយ។

កៈ
ជាមួយឪពុកម្តាយរបស់លោកពូថាមានការជូរជត់យ៉ាងម្តេចពីជំនាន់មួយទៅជំនាន់មួយទៀតនិងលោកពូ។

ខៈ បាទ!
ជំនាន់និងវាជូរជត់ណាស់កាលពីជំនាន់និងលន់នល់និងមានការលំបាកណាស់យើងរត់ទៅហើយគេតាមទម្លាក់គ្រាប់បែកតាមអូរនិងហើយរត់ទៅពួនតាមព្រៃឈើនិងហើយពេលនិងមានផ្ទះណាតាមស្រុកស្រែចំការនិងមានតែស្រែចំការនិងហើយវាដាក់គ្រាប់ផ្លោនមកខ្ទិចផ្ទះអស់ហើយនិង។

កៈ បាទ! អញ្ជឹងលោកពូមានការលំបាកច្រើនលោកពូ។

ខៈ បាទ !

កៈ បាទ! អញ្ជឹងមានធ្លាប់រត់ចូលព្រៃជាមួយពួកគាត់ញុំាពោតជាមួយពួកគាត់ទេលោកពូ។

ខៈ
ធ្លាប់តាខ្ញុំរត់ទៅព្រៃហើយខ្ញុំនៅផ្ទះម្តេចកើតព្រោះគេទម្លាក់គ្រាប់មកហើយមានរត់ទៅក្នុងព្រៃបើមិនរត់ទៅក្នុងព្រៃគេទម្លាក់គ្រាប់មកហើយរត់ទៅនៅផ្លង់តេនិងហើយនៅជាមួយគេដែរទៅ។

កៈ បាទ! ហើយនាំកូននាំចៅទៅនៅនិងទៅ។

ខៈ បាទ !នាំកូននាំចៅទៅនៅនិងទៅណា។

កៈ បាទ!

ខៈ បាទ! កាលពីជំនាន់និងគ្មាននាក់នៅផ្ទះទេ។

កៈ បាទ! ហើយអញ្ជឹងលោកពូហាលទឹកហាលភ្លៀងជាមួយពួកគាត់ទៅអញ្ជឹង។

ខៈ បាទ! ហាលទឹកហាលភ្លៀងជាមួយពួកគាត់ទៅណាស់។

កៈ ហើយអញ្ជឹងលោកពូមានអនុស្សាវរីយ៍ជូរជត់ច្រើនណាស់ពូណុស។

ខៈ បាទ!
មានច្រើនណាស់អនុស្សាវរីយ៍និងហើយពេលលឺថាគ្រាប់ផ្លោនមកហើយខ្លះច្រមុជក្នុងទឹកព្រាំងឈូកនិងទៅណា។

កៈ ច្រមុជក្នុងទឹកទៀតលោកពូ។

ខៈ បាទ!
ពេលគាត់បានឃើញយន្តហោះមកគាត់ចាប់កូនច្រមុជក្នុងទឹកទៅហើយពេលយន្តហោះនិងហោះទៅបាត់ទៅហើយគាត់ចាប់ទាញ់កូនមកវិញមកទៅហើយយន្តហោះនិងហោះមើលមនុស្សតែម្តងនិងហើយវាហោះទាបៗនិង។

កៈ បាទ!

ខៈ ហើយពេលឃើញយើងហើយចាំតែបាញ់យើងនិងហើយ។

កៈ បាទ! ហើយពេលនិងលោកពូដង្ហើមតាមណាទៅលោកពូ?

ខៈ កាលពេលនិងដង្ហើមតាមកំផ្លោតនិង។

កៈ អរលោកពូដង្ហើមតាមកំផ្លោតទេលោកពូ។

ខៈ បាទ ! ហើយពេលនិងឲ្យកូនច្រមុជមួយភ្លែតនិងលើកូនមកវិញហើយ។

កៈ បាទ! ហើយជាមួយបងប្អូនទៅលោកពូ។

ខៈ បាទ! ជាមួយបងប្អូនទៅ។

កៈ បាទ!
ហើយអញ្ចឹងលោកពូគាត់មានបានប្រាប់ពីខ្សែជីវិតរបស់គាត់កាលនៅពីក្មេងទេលោកពូ។

ខៈ គាត់បាននិយាយប្រាប់ខ្ញុំតា។

កៈ គាត់បាននិយាយប្រាប់ពូដែរលោកពូ?

ខៈ បាទ!

កៈ គាត់មានប្រាប់ពីប្រវត្តិគាត់មានការជូរជត់ដែរលោកពូ។

ខៈ បាទ! គាត់បានប្រាប់ខ្ញុំពីប្រវត្តិគាត់ជូរជត់តា។

កៈ បាទ !
គាត់ប្រាប់លោកពូថាកាលគាត់នៅពីក្មេងមានការជួបការលំបាកអីអញ្ចឹងទៅលោកពូ។

ខៈ បាទ!

កះ ហើយគាត់មានលំបាកទម្រនបានម៉ាក់លោកពូណាស់លោកពូ។

ខះ បាទ !

កះ
បាទ!លោកពូហើយអញ្ជឹងលោកពូមាននៅចាំឈ្មោះជីដូនជីតាខាងឪពុកម្តាយរបស់លោកពូទេ។

ខះ បើខាងជីដូនជីតាខាងម្តាយឈ្មោះ ស្រូយ យឹមខាងម្តាយ។

កះ បាទ!ឈ្មោះ ស្រូយ យឹម ខាងម្តាយ។

ខះ ខាងឪពុកឈ្មោះ ខឹម ឈឹង ខាងឪពុក។

កះ បាទ! ខឹម ឈឹង ខាងឪពុក ឈ្មោះទាំងអស់និងគុងឬម៉ាលោកពូ?

ខះ ឈ្មោះគុង។

កះ ហើយបើលោកយាយ។

ខះ ហើយបើយាយខាងឪពុកខ្ញុំវិញឈ្មោះយឹម ហឹម ហើយខាងម្តាយសយ យូត។

កះ បាទ!

ខះ ខាងម្តាយ។

កះ ហើយអញ្ជឹងលោកពូគាត់មានបានប្រាប់ថាគាត់កើតឆ្នាំណាអីលោកពូ?

ខះ គាត់អត់បានប្រាប់ផង។

កះ គាត់បានប្រាប់លោកពូផងលោកពូ។

ខះ បាទ!

កះ អញ្ជឹងលោកពូក្រុមគ្រួសារលោកពូគាត់រស់នៅខេត្ត កណ្តាលនិងទាំងអស់គ្នាលោកពូ។

ខះ បាទ!

កះ បាទ! ហើយអញ្ជឹងលោកពូមានបងប្អូននៅក្រៅប្រទេសទេលោកពូ?

ខះ អត់មានទេ។

ក៖ បាទ! អញ្ចឹងលោកពូអត់មានបងប្អូននៅក្រៅប្រទេសទេលោកពូ។

ខ៖ អត់មានទេ។

ក៖ ហើយបងប្អូនជីដូនមួយក៏អត់មានដែរ?

ខ៖ អត់មានផងនិង។

ក៖ បាទ!
អញ្ចឹងបើនិយាយពីអាពាហ៍ពិពាហ៍របស់លោកពូវិញតើភរិយារបស់លោកពូមានឈ្មោះអីគេដែរលោកពូ?

ខ៖ ប្រពន្ធរបស់ខ្ញុំឈ្មោះ ស៊ុន ។

ក៖ បាទ! ឈ្មោះ ស៊ុន។

ខ៖ តែបែកបាកពីខ្ញុំទៅគាត់ស្លាប់៦ឆ្នាំហើយ។

ក៖ បាទ!ហើយអញ្ចឹងគាត់បានបន្សល់ទុកកូនប៉ុន្មាននាក់ដែរលោកពូ?

ខ៖ កូនប្រាំបីនាក់។

ក៖ កូនប្រាំបីនាក់។

ខ៖ បានកូនប្រាំបីនាកហើយប្រពន្ធខ្ញុំគេស្លាប់បានបីឆ្នាំហើយកូនខ្ញុំស្លាប់មួយទៀតដែរនិង។

ក៖ បាទ!

ខ៖ និងបីឆ្នាំពីរ។

ក៖ បាទ! ហើយលោកពូស្រីប៉ុន្មានហើយប្រុសប៉ុន្មានលោកពូ?

ខ៖ កាលនិងស្រីបួនប្រុសបួនហើយឥឡូវនៅសល់តែស្រីបីប្រុសបួន។

ក៖ អញ្ចឹងនាក់ដែរស្លាប់និងស្រីលោកពូ។

ខ៖ បាទ! បានកូនពីរ។

ក៖ អរគាត់មានកូនពីរលោកពូ។

ខ៖ បាទ!

កៈ អញ្ចឹងលោកពូមានថៅពីរនាក់ហើយ។

ខៈ បាទ! ខ្ញុំមិនមែនមានថៅពីរទេខ្ញុំមានថៅបួនប្រាំ។

កៈ បាទ! អញ្ចឹងដល់ទៅបួនប្រាំនាក់ច្រើនដែរលោកពូ។

ខៈ បាទ!

កៈ បាទ!អញ្ចឹងលោកពូមាននៅចាំថាកូនរបស់លោកពូមានឈ្មោះអីទេលោកពូ?

ខៈ កូនទីប៉ុន្មានដែរ?

កៈ កូនទីមួយដែរស្លាប់ហើយនោះលោកពូ?

ខៈ កូនដែរស្លាប់និងកូនទី៣ទេ។

កៈ បាទ! អញ្ចឹងកូនទីមួយរបស់លោកពូមានឈ្មោះអីដែរលោកពូ?

ខៈ បើកូនទីមួយអត់ដឹងទេនាកទាល់តែមើលសៀវភៅគ្រួសារបានដឹងខ្ញុំចាំថាឌី វណ្ណៈ វណ្ណាហើយ ហុង ចាន់ណា ហុងស្រី៣ ហុង សំណាងហើយហុង បូរ៉ា បូរី ។

កៈ បាទ! ហើយអញ្ចឹងបងស្រីគាត់ស្លាប់យូរហើយលោកពូ?

ខៈ បាទ! គាត់ស្លាប់បានប្រាំពីរឆ្នាំហើយ។

កៈ បាទ! ហើយអញ្ចឹងអាពាហ៍ពិពាហ៍របស់លោកពូចាប់ផ្តើមនៅណាដែរលោកពូ?

ខៈ អាពាហ៍ពិពាហ៍ខ្ញុំចាប់ផ្តើមនៅខេត្ត កណ្តាលនិងហើយ។

កៈ បាទ! អញ្ចឹងលោកពូបានចាប់ផ្តើមនៅខេត្ត កណ្តាលនិងតែម្តងលោកពូ។

ខៈ បាទ!

កៈ ហើយលោកពូរៀបអាពាហ៍ពិពាហ៍និងបានប៉ុន្មានឆ្នាំហើយលោកពូ?

ខៈ បើនិយាយទៅយកគ្នានិងកូនខ្ញុំមានអាយុ ៣០ឆ្នាំហើយអញ្ចឹងបាន៣០ឆ្នាំហើយ។

កៈ អញ្ចឹងលោកពូការបានជិត៣០ឆ្នាំហើយលោកពូ។

ខៈ បាទ! ព្រោះអីខ្ញុំការតាំងពីឆ្នាំ១៩៨២។

កៈ បាទ! តាំងពីជំនាន់រដ្ឋកម្ពុជាមកលោកពូ។

ខ៖ បាទ!

ក៖ បាទ!
អញ្ចឹងកាលពីលោកពូបានចាប់ដៃគ្នាមកអញ្ចឹងលោកពូបានស្រលាញ់គ្នាឬក៏ឪពុកម្ដាយគាត់ជានាក់រៀបចំលោកពូ។

ខ៖
អត់ទេអត់បានស្រឡាញ់គ្នាផងនិងឪពុកម្ដាយគាត់ជានាក់រៀបចំឲ្យនិងដូចជាផ្ទះមួយគាត់ស្គាល់ផ្ទះមួយទៀតមានកូនក្រមុំនិងទៅអញ្ចឹងទៅគាត់រៀបចំឲ្យទៅដូចនៅភូមិជាមួយគ្នានិង។

ក៖ ហើយអញ្ចឹងកាលនិងលោកពូជូនជំនាន់គាត់ប៉ុន្មានដែរលោកពូ?

ខ៖ បាទ!

ក៖ ហើយកាលនិងលោកពូជូនជំនាន់គាត់ប៉ុន្មានដែរលោកពូ?

ខ៖
ហើយជំនាន់នោះដូចអញ្ចេកចាយមាសចាយអង្ករគេចង់ដៃនិងអង្ករនិងហើយនិងស្រូវនិងហើយអ្នកខ្លះយកមាន់និងណាស់។

ក៖ បាទ! កាលពីជំនាន់និងគេចាយអង្ករលោកពូ។

ខ៖ បាទ! កាលនិងគេចាយលុយយួនតែគេអត់ចាយចឹងគេចាយអង្ករទៅ។

ក៖
អញ្ចឹងលោកពូអាចប្រាប់ខ្ញុំបានទេថាលោកពូពេលដែលឪពុកម្ដាយគាត់ផ្សំផ្គុំលោកពូនិងតើលោកពូបានស្គាល់គ្នាពីមុនទៅហើយមានបានធ្លាប់ដើរលេងជាមួយគ្នាទេលោកពូ?

ខ៖ បាទ! ធ្លាប់តាព្រោះផ្ទះខ្ញុំនិងគេនិងនៅក្បែរគ្នាដែរនិង។

ក៖ បាទ! អញ្ចឹងលោកពូបានស្គាល់គ្នាហើយ។

ខ៖ បាទ! ធ្លាប់ស្គាល់គ្នាហើយធ្លាប់ដើរលេងជាមួយគ្នាទៀតហើយបានរៀនជាមួយគ្នា។

ក៖ បាទ! អញ្ចឹងលោកពូបានរៀនជាមួយគ្នាទៀតលោកពូ។

ខ៖ បាទ! រៀនជាមួយគ្នានិងហើយបានស្គាល់គ្នានិងណាជិះកង់ជាមួយគ្នា។

ក៖ បាទ! អញ្ចឹងលោកពូបានជិះកង់ជាមួយគ្នាទៀតលោកពូ។

ខ៖ បាទ! ហើយអញ្ចឹងទៅចាស់ៗគាត់ក៏ផ្សំផ្គុំគ្នាទៅ។

ក៖ បាទ!អញ្ចឹងចាស់គាត់ផ្សំផ្គុំគ្នាទៅ។

ខ៖ បាទ!

ក៖ ហើយអញ្ចឹងពេលនៅរៀននិងលោកពូមានឈ្លោះគ្នាអត់លោកពូ?

ខ៖ ដូចជាធ្លាប់ឈ្លោះគ្នាដែលតែឈ្លោះមួយប្រាវទៅហើយត្រូវគ្នាវិញ។

ក៖ បាទ!
ហើយលោកពូបានធ្លាប់ឈ្លោះគ្នាពេលបានស្រលាញ់គ្នាធ្វើប្តីប្រពន្ធម៉េចទៅលោកពូ?

ខ៖ អត់អីដែរនិងហើយដល់ពេលត្រូវគ្នាទៅជិះកង់ជាមួយគ្នាទៅ។

ក៖ បាទ!ជិះកង់ជាមួយគ្នាទៅលោកពូ។

ខ៖ បាទ!

ក៖ បាទ! ពេលដែលលោកពូនៅរៀននិងលោកពូធ្លាប់ប្រកួតប្រជែងគ្នាអត់លោកពូ?

ខ៖ ធ្លាប់តា។

ក៖ ធ្លាប់ប្រកួតប្រជែងគ្នាហើយធ្លាប់ឈ្លោះគ្នា។

ខ៖ បាទ! ពេលត្រូវគ្នាវិញជិះកង់ជាមួយគ្នាវិញទៅ។

ក៖ បាទ!
ហើយលោកពូនៅពេលជំនាន់និងលោកពូពេលដែលឪពុកម្តាយគាត់ផ្សំផ្គុំគ្នាលោកពូមានអារម្មណ៍ម៉េចដែរលោកពូ?

ខ៖
ខ្ញុំមានអារម្មណ៍ធម្មតាតែខ្ញុំអត់សូវពេញចិត្តដែលតែគេនិយាយជីដូនមួយឪពុកផងអញ្ចឹងណា។

ក៖ បាទ! ជីដូនមួយគ្នាលោកពូ។

ខ៖ បាទ!

ក៖ ហើយលោកពូសាច់ឆ្ងាយឬក៏សាច់ជិតលោកពូ?

ខ៖ សាច់ឆ្ងាយដែលនិងជិដូនមួយឪពុកខ្ញុំនិង។

ក៖ បាទ!

ខ៖ គាត់ផ្សំផ្គុំគ្នាទៅកុំដាច់សាច់និងណា។

ក៖ បាទ! ហើយធ្លាប់តែឈ្លេះគ្នាហើយម៉ែឪគាត់ផ្សំផ្គុំគ្នាអញ្ចឹងធ្លាប់អៀនគ្នាទេលោកពូ?

ខ៖ ដូចធម្មតា។

ក៖ បាទ! ដូចនៅពេលដែលឪពុកម្ដាយគាត់ផ្សំផ្គុំគ្នាអញ្ចឹងដំបូងឡើយអៀនគ្នាទេលោកពូ?

ខ៖
អៀនដែរតាពេលដឹងអញ្ចឹងណាដូចយើងទៅដើរលេងអីជាមួយគ្នាហើយទៅមើលកុនអីជាមួយនិងណា។

ក៖ បាទ ! អញ្ចឹងទៅអៀនគ្នាទៅលោកពូ?

ខ៖ បាទ!

ក៖ ពេលឃើញមុខគ្នាអីអត់ចឹងនិយាយរកគ្នាទេ។

ខ៖ បាទ!

ក៖ ហើយដល់ពីដឹងអញ្ចឹង។

ខ៖ ដល់អញ្ចឹងមានការអៀនរៀងខ្លួន។

ក៖ បាទ!
ហើយអញ្ចឹងលោកពូបានរៀនហើយបានអានភាសាខ្មែរបានច្បាស់ហើយលោកពូបានរៀនត្រឹមថ្នាក់ទីប៉ុន្មានដែរលោកពូ?

ខ៖ ខ្ញុំរៀនបានត្រឹមថ្នាក់ទីមួយនិង។

ក៖ បាទ!លោកពូរៀនបានថ្នាក់ទីមួយលោកពូ។

ខ៖ តែបើឲ្យមើលៗលែងឃើញហើយ។

ក៖ ខានរៀនយូរលោកពូតែលោកពូអាចមើលដាច់។

ខ៖ បាទ!

កៈ ហើយបើភាសាខ្មែរតើលោកពូមានចេះភាសាវៀតណាម ថៃ ឡាវអីទេលោកពូ?

ខៈ អត់ចេះទេខ្ញុំបានរៀនតែភាសាខ្មែរបានមួយមុខនិង។

កៈ បាទ!ៗ ហើយអញ្ចឹងសាលាលោកពូបានរៀននិងនៅណាដែរលោកពូ?

ខៈ សាលានិងនៅភូមិប្រាសាទដែលនិង។

កៈ នៅភូមិប្រាសាទនិងហើយអញ្ចឹងលោកពូមានចាំឈ្មោះសាលានិងទេលោកពូ?

ខៈ
សាលាកាលពីជំនាន់និងដូចជាគេអត់បានដាក់សាលាឈ្មោះអីទេព្រោះយើងទៅរៀនតាមផ្ទះនិង។

កៈ បាទ! ហើយអញ្ចឹងអត់ដឹងសាលាអីទេលោកពូ?

ខៈ បាទ!ៗ

កៈ យើងមិនអាចដឹងបានព្រោះអីទើបតែបៃបពីអាពតលោកពូ។

ខៈ បាទ!ៗ

កៈ ហើយអញ្ចឹងលោកពូមានស្គាល់ឈ្មោះគ្រូទេលោកពូ?

ខៈ
គ្រូៗកាលពីជំនាន់ពេលខ្លះគេចូលធ្វើទាហានហើយខ្លះអាពតយកទៅស្លាប់អស់ហើយគ្រូៗគេថាខ្សែចិននិងគេសម្លាប់អស់ហើយ។

កៈ អឺម៉េចអញ្ចឹងលោកពូ?

ខៈ ហើយតែឃើញថាស្បែកសៗនិងចោតថាចិនហើយនិងយួននិងសម្លាប់អស់ហើយ។

កៈ បាទ! ហើយអញ្ចឹងលោកពូនៅពេលនិងលោកពូសប្បុរខ្មៅក៏សលោកពូ?

ខៈ ខ្ញុំមានសប្បុរធម្មតានិងខ្មៅនិង។

កៈ បាទ!បានអញ្ចឹងបានថាខ្មែរលោកពូ?

ខៈ បាទ!

កៈ ហើយបើលោកពូសប្បុរសគេថាយួនដែរលោកពូ?

ខ៖
អត់ទេបើរៀងសប្បុរសដូចអូនឯងនិងគេថាយូនហើយនិងបើមិនយូនទេគេថាចិនយកទៅសម្លាប់ចោល។

ក៖ អរ តែឥឡូវនិងអ្នកសៗច្រើនណាស់លោកពូ?

ខ៖ បាទ! អ្នកសៗច្រើនណាស់ឥឡូវគ្មានគេសម្លាប់ចោលទេ។

ក៖ បាទ! មានតែគេទុក។

ខ៖ បាទ! មានតែគេទុកអភិវឌ្ឍន៍ព្រោះអីប្រទេសឥឡូវជឿនលឿន។

ក៖ ហើយអញ្ចឹងកូនលោកពូបានរៀបចំហើយអស់ហើយលោកពូ?

ខ៖ បាទ!

ក៖ ហើយអញ្ចឹងកូនលោកពូបានរៀបចំអស់ហើយលោកពូ?

ខ៖ មានគ្រួសារ អរ បានបួននាក់ហើយ។

ក៖ បាទ ! បានបួននាក់នៅសល់បួននាក់ទៀត។

ខ៖ បាទ! នៅសល់បួននាក់ទៀត។អត់ទេនៅសល់តែបីនាក់ទេម្នាក់បានស្លាប់ហើយ។

ក៖ បាទ!

ខ៖ បាទ! តែឥឡូវនៅសល់បីនាក់។

ក៖ បាទ! នៅសល់បីនាក់ហើយស្រីប៉ុន្មានហើយប្រុសប៉ុន្មានដែរលោកពូ។

ខ៖ នៅសល់ស្រីពីរប្រុសមួយ។

ក៖ បាទ! នៅសល់ស្រីពីរប្រុសមួយ។តែគាត់ឥឡូវនៅរៀនទេលោកពូ?

ខ៖ នៅធ្វើការរោងចក្រទាំងអស់គ្នាហើយ។

ក៖ បាទ! គាត់ទៅធ្វើការរោងចក្រអស់ហើយលោកពូ។

ខ៖ បាទ!

ក៖ អ្នកមានគ្រួសារនិងគេទៅអស់ហើយលោកពូ?

ខ៖ គេអ្នកមានគ្រួសារគេទៅអស់ហើយ។

ក៖ គេទៅនៅតាមគ្រួសារម៉ាម្ដុំៗទៅ។

ខ៖ បាទ! នៅតាមគ្រួសារគេនិងទៅ។

ក៖ បាទ! បើសូមបកក្រោយវិញតើបងប្អូនរបស់ពួកគាត់ទៅណាអស់ហើយលោកពូ?

ខ៖ បងប្អូនខ្ញុំនៅសៀមរាបបីនាក់។

ក៖ បាទ!

ខ៖ ហើយនៅខាងត្បូងនិងម្នាក់ហើយនៅប្រាសាទនិងពីរនាក់។

ក៖ បាទ! ហើយបងប្អូនរបស់មានដែលទាក់ទងគ្នាទេលោកពូ?

ខ៖ ទាក់ទងគ្នាតាតាមទូរស័ព្ទ។

ក៖ បាទ! អញ្ចឹងបងប្អូនរបស់លោកពូបានបែងចែកគ្នាអស់ហើយ។

ខ៖ បាទ!

ក៖ ពេលចូលឆ្នាំខ្មែរអី។

ខ៖ ពេលចូលឆ្នាំខ្មែរគាត់មកលេងទាំងអស់គ្នានិង។

ក៖ បាទ! មានបងប្អូនមកលេងទាំងអស់គ្នាអញ្ចឹងសប្បាយហើយអញ្ចឹងលោកពូ?

ខ៖ បាទ! គាត់មកលេងទៅវត្តជាមួយគ្នានិង។

ក៖ បាទ! សប្បាយហើយមានបងប្អូនមកលេងជុំគ្នានិង។

ខ៖ បាទ!

ក៖
សប្បាយដូចជាលក្ខណៈជាក្រុមគ្រួសារមួយដែរមានភាពសប្បាយហើយដូចគ្រួសារមួយល្អ
អញ្ចឹងលោកពូ។

ខ៖ បាទ!

ក៖ បាទ! និយាយពីការរៀនវិញតើលោកពូមានមិត្តភក្តិជិតស្និតប៉ុន្មាននាក់ដែរកាលពីនៅរៀនហើយមិត្តនៅក្នុងភូមិលោកពូ?

ខ៖ បាទ! មិត្តភក្តិច្រើនដែរនិង។

ក៖ បាទ!

ខ៖ តែដល់ពេលគេទៅឆ្ងាយអស់ទៅដល់ពេលចូលឆ្នាំនិងមកសុទ្ធតែមិត្ត។

ក៖ បាទ! អញ្ចឹងលោកពូពេលចូលឆ្នាំម្តងសប្បាយណាស់មានមិត្តច្រើន។តែសុទ្ធតែមិត្តភក្តិជិតស្និតលោកពូតែធ្លាប់ដើរលេងគ្នានិងលោកពូ?

ខ៖ មិត្តភក្តិនិងធ្លាប់ដេកមុងជាមួយគ្នា។

ក៖ បាទ! ធ្លាប់ដេកមុងជាមួយគ្នាទៀតលោកពូ?

ខ៖ បាទ! អាពីរបីនាក់និង។

ក៖ បាទ!

ខ៖ តែឥឡូវវាទៅថៃទៅ។

ក៖ ហើយអញ្ចឹងលោកពូមានស្គាល់ឈ្មោះពួកគាត់ទេ។

ខ៖ ស្គាល់តា។

ក៖ មានឈ្មោះអីគេដែរលោកពូ?

ខ៖ មានឈ្មោះអាវ៉ាន់ អាធី អាថា អាចុន អាប៊ុន ហើយអាចិត្ររិទ្ធ។

ក៖ ចិត្ររិទ្ធ មានតែប្អូនប្រាំនាក់និងទេលោកពូ។

ខ៖ មានតែប្អូនប្រាំនាក់និង។

ក៖ បាទ! ធ្លាប់ដើរលេងជាមួយគ្នាទៅលោកពូ។

ខ៖ បាទ! ធ្លាប់ដើរលេងជាមួយគ្នានិងពេលមានរវល់បុណ្យអីមក។

ក៖ បាទ! មានធ្លាប់ទៅញ៉ែស្រីជាមួយគ្នាទេលោកពូ?

ខ៖ បាទ!
ធ្លាប់តាទៅញ៉ែគេហើយបើស្រលាញ់គ្នាហៅម៉ែឪទៅមើលអីអញ្ចឹងនិងណាពេលម៉ែឪគេពេញចិត្តគេការទៅណា។

ក៖ បាទ!
ពេលចូលឆ្នាំបុណ្យទានម្តងៗទៅរាំវង់អីពេលឃើញកូនក្រមុំគេអញ្ចឹងហើយឃើញកូនស្រីគេស្អាតៗមានទៅញ៉ែតាមគេដល់ផ្ទះអីលោកពូ។

ខ៖ បាទ! ពេលនិងចេះតែចង់ញ៉ែហើយ។

ក៖ បាទ! ពេលនិងលោកពូនៅស្អាត់ដែរនិង។

ខ៖ បាទ!

ក៖ លោកពូឥឡូវនៅស្អាត់នៅកាលពីក្មេងទៀតស្អាត់ប៉ុណ្ណាទៅ។

ខ៖ បាទ!

ក៖ បាទ!
ហើយអញ្ចឹងលោកពូបើនិយាយកាលពីក្មេងមករហូតដល់ធំនិងលោកពូមានធ្លាប់ស៊ីឈ្នួលគេធ្វើការដកស្ទូងគេទេលោកពូ?

ខ៖ បាទ! ខ្ញុំធ្លាប់តាស៊ីឈ្នួលគេតាដកស្ទូងគេ។

ក៖ បាទ!នៅពេលនិងគេហៅថ្លូនបានប៉ុន្មានដែរលោកពូ?

ខ៖ ជំនាន់នៅគេស្ទូងនិងគេគិតថ្ងៃវិញនិង។

ក៖ បាទ! គេគិតថ្ងៃវិញលោកពូ។

ខ៖ បាទ! គេគិតថ្ងៃគេគិតលុយឃ្យូនពេលនិងយើងចាយលុយឃ្យូន។

ក៖ បាទ!

ខ៖ បាទ!
ពេលនិង១រៀល២រៀលដូចស្ទូងហើយពេលខ្លះយើងប្រវាសគ្នាទេដូចខ្ញុំជួយមួយថ្ងៃនិង។

ក៖ បាទ!

ខ៖
ដូចគេមានការរស់អញ្ចឹងទៅយើងជួយគេដូចប្រាំថ្ងៃអីអញ្ចឹងទៅហើយពេលយើងមានការរ
ស់វិញគេមកជួយយើងប្រាំថ្ងៃវិញទៅណាអ្នកភូមិនិងគេអត់សូវគិតលុយទេភូមិនិងនោះ។

ក៖ បាទ!

ខ៖ យើងជួយគ្នាទៅ។

ក៖ បាទ! ដូចអញ្ចឹងយើងអត់បានប្រាក់កំរៃអីទេ។

ខ៖ បាទ!

ក៖ អញ្ចឹងក្រៅពីដកស្ទូងនិងលោកពូមានធ្លាប់ស៊ីឈ្នួលអីផ្សេងទេលោកពូ?

ខ៖
ស៊ីឈ្នួលដូចធ្វើកម្មករឡូអីអញ្ចឹងណាស់ហើយបានប្រាក់ខែបួនដប់ម៉ឺនអីអញ្ចឹងណាស់។

ក៖ បាទ! ហើយអញ្ចឹងដូចពេលដាច់ពីសម័យអាពតនិង។

ខ៖ បាទ !ពេលដាច់សម័យប៉ុលពតនិងខ្ញុំធ្វើកម្មករឡូគេនិង។

ក៖ បាទ!
អញ្ចឹងលោកពូបើនិយាយពីជីវិតនៅក្នុងគ្រួសារវិញលោកពូពេលដែរលោកពូបានចាប់ដៃជា
មួយអ្នកមីងតើលោកពូមានការជួបការជូរជត់ដែរឬទេហើយមានការជួបឧបសគ្គអីគេដែរ
លោកពូ?

ខ៖ មានជួបឧបសគ្គច្រើន។

ក៖ បាទ! អញ្ចឹងលោកពូបានជួបឧបសគ្គអ្វីដែរលោកពូ?

ខ៖
ដូចជាពេលដែលឪពុកម្តាយគាត់ផ្សំផ្គុំមានការខ្វះខាតច្រើនដែលហើយដូចចង់បានម៉ូតូយើ
ងត្រូវចងការលុយគេមានការលំបាកណាស់។

ក៖ បាទ! ពេលដែលចាប់ដៃគ្នាមកមានការលំបាកច្រើន។

ខ៖ បាទ! មានការលំបាកគ្នាច្រើនណាស់។

ក៖ បាទ!

ខ៖ យើងមានកូនច្រើនអញ្ចឹងយើងត្រូវការច្រើនអញ្ចឹងណាស់។

ក៖ បាទ! ហើយអញ្ចឹងបងស្រីធ្វើអីដែរលោកពូ?

ខ៖ គាត់គ្មានធ្វើអីទេគាត់នៅផ្ទះទេ។

ក៖ បាទ!

ខ៖ គាត់ធ្វើការលក់ឥវ៉ាន់នៅផ្ទះហើយគាត់ចិញ្ចឹមជ្រូកនៅផ្ទះតិចតួចនិង។

ក៖ បាទ!គាត់ចិញ្ចឹមជ្រូក។ហើយអញ្ចឹងពេលនិងលោកពូប្រកបមុខរបរអ្វីដែរលោកពូ?

ខ៖ ខ្ញុំនៅពេលនិងខ្ញុំនេសាទនិង។

ក៖ បាទ!លោកពូនេសាទលោកពូនៅណាដែរលោកពូ។

ខ៖ ខ្ញុំនេសាទនៅបឹងភូមិប្រាសាទនិង។

ក៖ បាទ! នៅភូមិប្រាសាទនិងបឹងប្រាសាកនិងដែរទៅលោកពូ?

ខ៖ ខ្ញុំនេសាទនៅភូមិប្រាសាទស្រុកស្អាងយើង។

ក៖ បាទ! យើងបានតិចតួចយើងយកទៅលក់ទៅ។

ខ៖ បាទ! បានតិចតួចនិងយើងយកទៅលក់ទៅ។

ក៖ បាទ !

ខ៖ ហើយយកទៅទិញឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃនិងខ្លះទៅណា។

ក៖ លោកពូចេះតែរួមផ្សំគ្នាទៅហើយចេះតែក៏កើតជាក្រុមគ្រួសារទៅលោកពូ?

ខ៖ បាទ!

ក៖
ហើយមកដល់ពេលនេះលោកពូបានស្រួលហើយលោកពូព្រោះអីកូនរបស់លោកពូគាត់ធំៗអស់ហើយលោកពូ។

ខ៖ បាទ!ឥឡូវខ្ញុំគេបានការងារអស់ហើយឥឡូវតែខ្ញុំវាអត់បានសូវធូរទេ។

ក៖ បាទ! ហើយលោកពូមកធ្វើផ្ទះឲ្យគេទៅលោកពូ?

ខ៖ បាទ!

ក៖ ហើយលោកពូបានចំណេញបានច្រើនទេលោកពូ?

ខ៖
អត់សូវបានចំណេញទេព្រោះពេលទទួលគេមកបាន១០០០ដូល្លាអីបើបានចំណេញបាន២០០ដូល្លាដែរ។

ក៖ បាទ!
អញ្ជឹងលោកពូតាំងពីលោកពូនៅពីក្មេងរហូតមកដល់ធំហើយរហូតលោកពូមានគ្រួសារតើនៅក្នុងជីវិតរបស់លោកពូមានការផ្លាស់ប្តូរអ្វីខ្លះនៅក្នុងជីវិតរបស់លោកពូ?

ខ៖ បាទ!
មានការលំបាកដែរដោយសារពេលនៅជំនាន់អាពតបីឆ្នាំប្រាំបីខែយើងអត់ស្មារតីម៉ាសារហើយពេលដែរយើងមានកូនទៀតពេលយើងអត់ស្មារតីម៉ាសារទៀតណាស់តែយើងនៅតែខំប្រឹងរកស៊ីចិញ្ចឹមជីវិតប្រចាំថ្ងៃដើម្បីរកអនាគត់កូននៅក្រោយៗទៀតណាស់។

ក៖ បាទ! លោកពូចេះតែតស៊ូចិញ្ចឹមកូនទៅ។

ខ៖ បាទ!ៗចេះតែតស៊ូចិញ្ចឹមកូនទៅណាស់។

ក៖ បាទ!
អញ្ជឹងបានប្រាប់តាំងពីដំបូងមកនិងពេលឪពុកម្តាយលោកពូបានផ្សំផ្គុំគ្នានិងលោកពូអត់មានអីទេហើយពេលលោកពូបានចាប់ដៃគ្នាមកលោកពូបានខំប្រឹងរកស៊ីដោយខ្លួនឯងនិងទៅលោកពូ?

ខ៖ បាទ!លំបាករល្មមមកដល់សព្វថ្ងៃនេះ។

ក៖ បាទ! អញ្ជឹងលោកពូខំប្រឹងតាំងពីបាតដៃទទេមករហូតមកដល់សព្វថ្ងៃនេះលោកពូ។

ខ៖ បាទ! ខ្ញុំខំប្រឹងតាំងពីបាតដៃទទេមក។

ក៖ បាទ! ហើយព្យុះភ្លៀងជាមួយគ្នាទៅលោកពូ?

ខ៖
ឆ្លងកាត់ព្យុះភ្លៀងជាមួយគ្នាទៅគាត់ធ្លាប់នេសាទត្រីជាមួយគ្នាហើយឆ្លងកាត់រលកទឹកជាមួយគ្នា។

ក៖ បាទ! ហើយអញ្ជឹងប្រពន្ធរបស់លោកពូគាត់កាចទេលោកពូ?

ខៈ គាត់អត់កាចទេ។

កៈ គាត់អត់កាចទេលោកពូ។

ខៈ បាទ!ហើយខ្ញុំបានដឹងចិត្តគ្នាតាំងពីរៀនជាមួយគ្នាហើយនិង។

កៈ បាទ!
អញ្ចឹងលោកពូបើនិយាយពីមុខម្ហូបវិញតើលោកពូចូលចិត្តមុខម្ហូបអីជាងគេលោកពូ?

ខៈ បើនិយាយពីមុខម្ហូបនិងខ្ញុំចូលចិត្តមុខម្ហូបសម្លខ្មែរយើងនិងដូចសម្លគកូរ
ប្រហើរខ្ញុំចូលចិត្តជាងគេបើគ្រួសាររបស់ខ្ញុំវិញគាត់ចូលចិត្តស្ងោរ ចៀនជាងគេ។

កៈ បាទ!
បើនិយាយពីមុខម្ហូបប្រចាំគ្រួសាររបស់លោកពូហើយបើនិយាយឲ្យស្រួលប្រចាំត្រកូលរប
ស់លោកពូមុខម្ហូបអ្វីដែរលោកពូ?

ខៈ បើម្ហូបត្រកូលរបស់ខ្ញុំ ខ្ញុំចូលចិត្តសម្ល ម្ជូល កកូរ ប្រហើរហើយ សម្លត្រពាំង
សម្លក់អីណាស់។

កៈ បាទ! ប្រហើរដែរលោកពូ។

ខៈ បាទ! ប្រហើរដែរនិង។

កៈ បាទ! បើម្ជូលគ្រឿងចូលចិត្តទេលោកពូ?

ខៈ ម្ជូលគ្រឿងនិងមិនសូវទេ។

កៈ បាទ! បើប្រហុកចិញ្ច្រាំមលោកពូចូលចិត្តទេលោកពូ?

ខៈ បើប្រហុកចិញ្ច្រាំមនិងខ្ញុំចូលចិត្ត។

កៈ បាទ !ប្រហុកចិញ្ច្រាំមដាក់ផ្លែយើងលោកពូ។

ខៈ ផ្លែត្រសាំង។

កៈ បាទ! ផ្លែត្រសាំង។

ខៈ បាទ !ហើយដាក់ជាមួយស្រដាន់។

កៈ បាទ!ឆ្ងាញណាស់លោកពូ។

ខ៖ បាទ! ហើយផ្លែស្រដាន់បើខែវស្សាឆ្ងាញជាងនៅខែប្រាំង។

ក៖ បាទ! អញ្ចឹងលោកពូបើនិយាយពីល្បែងប្រជាប្រិយវិញដូចជាល្បែង ចោលឈូង បោះអង្គុញ ទាញព្រ័ត
លាក់កន្សែងហើយតើលោកពូចូលចិត្តលេងល្បែងប្រជាប្រិយមួយណាដែរលោកពូ?

ខ៖
ខ្ញុំចូលចិត្តលេងល្បែងប្រជាប្រិយដូចជាលាក់កន្សែងដែរព្រោះចូលចិត្តរត់លេងសប្បាយហើយបានដេញគុបគ្នាទៅវិញទៅមកនិង។

ក៖ បាទ! ពេលឆ្នាំខ្មែរតាមវត្តតាមអីអញ្ចឹងទៅលោកពូ?

ខ៖ បាទ !

ក៖ បើរាំហើយនិងច្រៀងលោកពូចូលចិត្តទេលោកពូ?

ខ៖ ខ្ញុំបើរាំខ្ញុំអត់ចេះរាំទេតែបើលេងល្បែងទាញព្រ័តអីខ្ញុំចូលចិត្ត។

ក៖ បើទាញព្រ័តលោកពូចូលចិត្ត។

ខ៖ បាទ!

ក៖ បើការច្រៀងវិញលោកពូចេះច្រៀងទេលោកពូ។

ខ៖ អត់ចេះច្រៀងទេ។

ក៖ អត់ដឹងថាច្រៀងម្ដេចលោកពូ។

ខ៖ បាទ! អត់ដឹងច្រៀងម្ដេច។

ក៖ បាទ
!ហើយអញ្ចឹងលោកពូបើនិយាយបងប្អូនរបស់ហើយបងប្អូនជីដូនមួយអីមាននរណាគេចេះលេងឧបករណ៍តន្ត្រីដូចជា ស្គរ ខ្លុយ រណាត ហ្គីតា ព្យាណូ ឈិង ចាប៉ី
អ្នកលេងភ្លេងបុរាណ ហើយសម័យទេលោកពូ?

ខ៖ អត់មានទេ។

ក៖ បាទ! ហើយកូនចៅអត់ចេះដែរលោកពូ?

ខ៖ បាទ! អត់មានទេជីដូនជីតាក៏មានដែរ។

កៈ
អញ្ចឹងលោកពូបើនិយាយអំពីផ្ទះរបស់លោកពូវិញដែរលោកពូរស់នៅជាមួយឪពុកម្ដាយរបស់មានសភាពបែបណាដែរលោកពូផ្ទះឈើឬផ្ទះស្បៅលោកពូ?

ខៈ
កាលពីសម័យប៉ុលពតគេបានវាយផ្ទះធំអត់ហើយគេយកជើងសសរហើយគេយករបស់ខ្ញុំនិងទៅធ្វើសហាករហើយពេលដល់ខែទឹកឡើងមកខ្ញុំទៅកាប់អាស្សីមកធ្វើជើងសសរ។

កៈ បាទ! ហើយដំបូលអីដែរលោកពូ។

ខៈ ដំបូលស្លឹកគប់យើងនិង។

កៈ បាទ! ស្លឹកគប់យើងនិង។

ខៈ គប់ជ្រុង។

កៈ បាទ! គប់ជ្រុង។

ខៈ បាទ!

កៈ ហើយជញ្ជាំងអ្វីដែរលោកពូ?

ខៈ ជញ្ជាំងក៏គប់ជ្រុងដែរនិងហើយខ្ញុំយកខ្សែមកចងតឹប។

កៈ បាទ! យកមកតឹបៗជាប់គ្នាទៅ។

ខៈ បាទ!

កៈ ហើយជើងសសរជើងសសរអាស្សី។

ខៈ បាទ! ជើងសសរអាស្សី។

កៈ ហើយកាំជណ្ដើរអីដែរលោកពូ?

ខៈ កាំជណ្ដើរអាស្សីដែរនិង។

កៈ បាទ! កាំជណ្ដើរអាស្សីដែរលោកពូ។

ខៈ បាទ!វាអាស្សីមែនពិតយើងដាបវា។

កៈ ដាបវាប្រហូងហើយដាក់ចូលក្នុង។

ខ៖ បាទ! ហើយយើងចុសវាប៉ុន្មានម៉ែត្រមកហើយយើងដាក់វាចូលទៅ។

ក៖ អរបាទ!ហើយដាក់ចូលទៅ។

ខ៖ បាទ! យើងសូកចូលសងខាងទៅ។

ក៖ បាទ! ហើយវាយធ្វើប្រកាន់ដៃទៅ។

ខ៖ បាទ! វាយធ្វើប្រកាន់ទៅ។

ក៖ បាទ!

ខ៖ ហើយពេលនិងជើងសសរផ្ទះខ្ញុំ១៥ដើម។

ក៖ បាទ!
ហើយអញ្ចឹងពេលនិងលោកឪពុកអ្នកម្ដាយរបស់លោកពូធ្វើផ្ទាល់ឬគាត់ជួយគេលោកពូ?

ខ៖ បាទ! ពេលនិងគេអត់ជួយទេគេលើកដៃគ្នាជួយធ្វើគ្នានិង។

ក៖ បាទ! ដូចថាជួយគ្នាម៉ាដៃម៉ាជើងទៅ។

ខ៖ បាទ!
គេជួយគ្នាទៅវិញទៅមកដូចថាជួយធ្វើផ្ទះមួយរួចទៅហើយទៅជួយផ្ទះគេវិញទៅ។

ក៖ បាទ! ហើយអញ្ចឹងពេលនិងមានសម្ភារៈអីគេខ្លះទៅពេលនិងដូចជាពូថៅ។

ខ៖ បាទ! ពូថៅ រណា ដែកដាប ប្រលៀក អីអញ្ចឹងណាស់។

ក៖ បាទ! ហើយអស្សី។

ខ៖ បាទ! អាស្សីយើងដាំក្រោយផ្ទះនិង។

ក៖ បាទ!
អញ្ចឹងមានបានបន្តវេនពីគ្រួសាររបស់ហើយដូចជាការបន្តវេនពីឪពុកម្ដាយដូចជាក្បូរត្នោត ត្បាញកន្ទេល ត្បាញក្រមា ធ្វើស្លឹកគប់ទេលោកពូ?

ខ៖ អត់ចេះទេ។

ក៖ លោកពូអត់បានបន្តវេនពីឪពុកម្ដាយទេ។

ខ៖ បាទ!

កៈ ហើយលោកពូចេះធ្វើផ្ទះឲ្យលោកពូចេះតាមពីណាគេដែរលោកពូ?

ខៈ
ខ្ញុំចេះតាមមេជាងដូចយើងតាមគាត់ហើយគាត់ម៉ៅគេហើយយកយើងទៅតាមអញ្ចឹងទៅខ្ញុំចេះទៅ។

កៈ អញ្ចឹងលោកពូចេះតែធ្វើផ្ទះឈើទេលោកពូ?

ខៈ បាទ! ផ្ទះឈើហើយផ្ទះថ្មក៏ចេះដែរ។

កៈ បាទ!លោកពូអាចធ្វើបានទាំងពីលោកពូ។

ខៈ បាទ!
ពេលយើងដើរជាមួយមេជាងគាត់ផ្ទះថ្មយើងធ្វើផ្ទះថ្មទៅហើយបើគាត់ម៉ៅផ្ទះឈើយើងធ្វើផ្ទះឈើទៅណា។

កៈ បាទ! ហើយគេធ្វើថ្មៗទៅហើយឈើៗទៅ។

ខៈ បាទ!

កៈ ហើយអញ្ចឹងលោកពូជានាក់ស្រុកស្អាងទេលោកពូ។

ខៈ បាទ! អ្នកស្រុកស្អាងទេ។

កៈ បាទ! ហើយគេហៅមកម៉ៅហើយធ្វើតាមស្រុកទៅ។

ខៈ បាទ! គេតែតាមទូរស័ព្ទទៅក៏មកធ្វើទៅ។

កៈ បាទ! ហើយមកធ្វើនៅគៀនស្វាយទៅ។

ខៈ បាទ! ដូចយើងធ្វើគេហើយធ្វើស្អាយទៅហើយគេតែហៅទៅ។

កៈ បាទ!
ហើយអញ្ចឹងលោកពូមានពាក្យផ្ដែផ្ដាំចុងក្រោយទៅកូនចៅរបស់លោកពូថាអ្នកជំនាន់មុខមានការលំបាកហើយមានការជួបឧបសគ្គហើយមានជូរជត់ជាច្រើននៅក្នុងជីវិតហើយមានពាក្យចងផ្ដាំផ្ញើរទៅកូនចៅលោកពូទេ?

ខៈ
ហើយពេលខ្លះមានការខឹងខ្លះដែលហើយពេលខ្លះមកលេងជាមួយដូចជាទៅវាច្រលមានខឹងដែរមិនថាអត់មានទេ។

កៈ បាទ!ហើយកូនលោកពូមានធ្លាប់វាយកូនទេលោកពូ។

ខៈ អត់សូវទេតែខ្ញុំមើលមុខទៅហើយវាឈប់ទៅណា។

កៈ គាត់ខ្លាចលោកពូដែរលោកពូ?

ខៈ បាទ!

កៈ បាទ! តែឥឡូវគាត់នៅតែខ្លាចលោកពូតាលោកពូ?

ខៈ បាទ! នៅតែខ្លាចខ្ញុំតា។

កៈ
ហើយអញ្ជឹងលោកពូតាំងពីតូចរហូតដល់ធំនិងពេលដែលលោកពូបានចូលរៀនរហូតមកអញ្ជឹងលោកពូមានក្ដីស្រមៃហើយមានបំណងថារៀនចប់ចងធ្វើជាគ្រូបង្រៀនហើយជាលោកគ្រូពេទ្យទេលោកពូ?

ខៈ កូនខ្ញុំមែន។

កៈ អត់ទេលោកពូតែម្ដងនិងលោកពូ?

ខៈ
តាំងពីក្មេងយើងចេះតែចងបានហើយប៉ុន្តែវាអត់អាចដូចគ្រួសារគេអញ្ជឹងណាហើយការសិស្សាយើងនៅខ្សោយជាងគេហើយយើងអត់មានឱកាសអញ្ជឹង។

កៈ អញ្ជឹងយើងបានត្រឹមប្រើកម្លាំងបាយដើម្បីរកលុយលោកពូ។

ខៈ យើងបានប្រើកម្លាំងហើយដូចគេថាប្រើញើសឈាមដើម្បីរកលុយអញ្ជឹង។

កៈ បាទ! ប្រើកម្លាំងពលកម្មទាំងអស់អញ្ជឹងលោកពូ។

ខៈ បាទ! យើងប្រើកម្លាំងពលកម្មពេលខ្លះប្រើខួរក្បាលខ្លះដែរ។

កៈ បាទ!
ហើយអញ្ជឹងជាចុងក្រោយកូនចៅជំនាន់ក្រោយដែរលោកពូចងប្រាប់ថាអ្នកជំនាន់មុខមានការលំបាកជាច្រើនហើយលោកពូចង់ឲ្យគាត់ធ្វើអីដែរលោកពូ?

ខៈ
ខ្ញុំចង់ប្រាប់កូនចៅជំនាន់ក្រោយត្រូវខំរៀនហើយកុំប្រព្រឹត្តិអំពីដែរសង្គមគេស្អីខ្ពើមអញ្ជឹងណាស់។

ក៖ បាទ! ៗសូមឲ្យគាត់ខំប្រឹងរៀនហើយឲ្យចៅខំប្រឹងរៀនដែរ។

ខ៖ សូមឲ្យគាត់ខំប្រឹងរៀនហើយឲ្យចៅខំប្រឹងរៀនដែរ។

ក៖ អញ្ចឹងលោកពូដែរលោកពូចង់ឲ្យគាត់ជៀសវាងអីដែរលោកពូ?

ខ៖ ឲ្យជៀសវាងគ្រឿងញៀន។

ក៖ បាទ!គ្រឿងញៀនហើយល្បែងពាលាហើយបងតូចបងធំ។

ខ៖ ដូចល្បែងពាលាបងតូចបងធំ។

ក៖ បាទ!

ខ៖ កុំប្រព្រឹត្តិអំពើដែរសង្គមគេស្អប់ខ្ពើមអញ្ចឹងណា។

ក៖ បាទ!

ខ៖ បើកូនចៅខ្ញុំអត់ឲ្យប្រព្រឹត្តិអញ្ចឹងទេ។

ក៖ បាទ! អញ្ចឹងលោកពូមានពាក្យបន្ថែមទៀតទេលោកពូ។

ខ៖ បានហើយ។

ក៖ បាទ!
បានហើយលោកពូ។ជាចុងក្រោយខ្ញុំសូមអរគុណលោកពូដែរបានញែកពេលដែរមានតម្លៃដែលមកកាន់សាកលវិទ្យាល័យរបស់ខ្ញុំលោកពូសូមលោកពូមានសុខភាពល្អហើយសូមឲ្យកូនចៅរបស់លោកពូរកស៊ីមានបានណាស់លោកពូអញ្ចឹងលោកពូអនុញ្ញាតឲ្យខ្ញុំយកសម្លេងរបស់លោកពូទៅសាលាបានទេលោកពូ។

ខ៖ បាន។

ក៖ បានអរគុណលោកពូ។